# កិច្ចសំភាសន៍របស់អ៊ី នួច សុភាព

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវបានគេសំភាសន៍ នួច សុភាព

កៈ ជាដំបូងជំរាបសួរអ៊ី!

ខៈ ចាស! ជំរាបសួរ!

កៈ ចាស! អ៊ីអ៊ី....ថ្ងៃនេះខ្ញុំមានឪកាលដើម្បីមកសំភាសន៍អ៊ីផ្ទាល់ ហើយខ្ញុំបានធ្វើការស្ម័គចិត្តនៅក្នុងគំរោងរបស់ខាងសាលា BYU ហាវៃនៅខាងសហរដ្ឋអាមេរិច ហើយខាងគំរោងរបស់សាលាមួយនិងគឺគេអ៊ី....បានធ្វើការសំភាសន៍ប្រជាជនកម្ពុជាដែលមានវ័យចាប់ពី៣៥ឆ្នាំឡើងទៅអំពីពង្សប្រវត្តិរបស់គាត់និងជីវិតនៃការតស៊ូរបស់គាត់និងអំពីបទពិសោធន៍ជីវិតដែលគាត់បានធ្លាប់ឆ្លងកាត់បីមុនមកគេចង់ចងក្រងវាមកដើម្បីទុកជាឯកសារដើម្បីអោយកូនចៅជំនាន់ក្រោយទៀតគេបានស្តាប់និងស្វែងយល់អំពីប្រវត្តិមុនៗនិងណាស់ (មានសំលេងរំខានពីខាងក្រៅ)!

ខៈ ចាស!

កៈ ចាស! អ៊ីហើយថ្ងៃនេះខ្ញុំមានឪកាសដើម្បីមកធ្វើការសំភាសន៍អ៊ីផ្ទាល់ អញ្ចឹងអ៊ីអាចអនុញ្ញាតអោយខ្ញុំធ្វើការថតសំលេងរបស់អ៊ីដើម្បីធ្វើការយកទៅផុសនៅក្នុង Website ដើម្បីអោយគេបានស្តាប់បានដែលឬទេអ៊ី?

ខៈ ចាស! (មានសំលេងរំខានពីខាងក្រៅ)

កៈ ចាស! អ៊ី

ខៈ អ៊ឺ....កាលពីដើមកាលពីខ្ញុំអាយុដប់ឆ្នាំឡើងទៅវាពិបាកណាស់អូនអើយគ្រួសារក៏ក្រ ឪពុកក៏ស្លាប់ចោលតាំងពីកៅប្រាំបួនមកម្លេះ (ឆ្នាំ១៩៩៩) ម្តាយរបស់ខ្ញុំគាត់មេម៉ាយតាំងពីខ្ញុំអាយុ១៧ឆ្នាំមក អញ្ចឹងការតស៊ូរបស់ខ្ញុំអត់ដែលបានរៀនសូត្រទេ រៀនបានតិចតួចណាស់ខ្ញុំរៀនបានត្រឹមតែថ្នាក់ទីពីរទេតស៊ូចេញមកធ្វើពលករគេ

យើងធ្វើការអោយគេតាមផ្ទះតាមអីនិង
អញ្ចឹងប្រាក់ខែក្នុងមួយខែៗបានតែប៉ូនម៉ឺនលុយខ្មែរយើងនិងទេ
មកដល់បច្ចុប្បន្ននេះខ្ញុំក៏លំបាកដែលវាគ្រាន់តែថារយះពេលជាងដប់ឆ្នាំនិង
គឺខ្ញុំលំបាកណាស់ហត់នឿយណាស់ចង់ថាគិតពេលវេលាមួយពេលដែលយើងគិតសព្វទៅៗ
ចង់គិតថាចង់តូចចិត្តនិងខ្លួនឯងណាស់ថាហេតុអ្វីបានជាក្រៗយ៉ាងនិង
កើតមកជាជីវិតនិងគេម្នាក់ដែរហេតុអ្វីបានជាក្រៗយ៉ាងនិងខុសគេខុសឯងជូនកាលចង់ស្លាប់
អោយផុតៗទៅ!

គ៖ ឥឡូវលែងក្រហើយអី!

ខ៖
គិតសព្វៗទៅគិតវែងឆ្ងាយកាលណាបើស្លាប់យើងមួយទៅចុះម្ដាយហើយប្អូនៗទៅទីពឹងអ្នក
ណា!

ក៖ ចាស!

ខ៖ បើយើងស្លាប់ទៅមួយទៅយើងជាកូនច្បងគេណាស់
ដល់ពេលអញ្ចឹងបើកាលណាយើងស្លាប់ទៅយើងបញ្ចប់ជីវិតយើងទៅ
តើឪពុកម្ដាយយើងបងប្អូនយើងវាលំបាកប៉ុណ្ណា
អញ្ចឹងយើងត្រូវតែតស៊ូៗរយះពេលដប់ឆ្នាំជាងហើយ
យើងតស៊ូណាស់អូនតស៊ូរហូតតែបងប្អូនរៀបការមានប្ដីមានប្រពន្ធទៅបានយើងចាប់ផ្ដើមបាន
ធូរធារបន្តិច វាមិនទាន់ធូរធារខ្លាំទេប៉ុន្តែគ្រាន់តែថា
វាអាចដោះស្រាយជីវភាពខ្លួនឯងបន្ទុកខ្លួនឯងបានខ្លះ
ដើម្បីកុំអោយវានៅក្នុងខ្លួនយើងនិងខ្លាំងពេកអោយគេជួយរំលែកយើងខ្លះទៅ
យើងវែកធ្ងន់យូរណាស់ហើយ អញ្ចឹងយើងដោះស្រាយបានបន្តិចៗហើយ!
(មានសំលេងរំខានពីខាងក្រៅ)

ក៖ ចាស!

ខ៖ អឹម....

ក៖ អញ្ចឹងតើអីមានឈ្មោះអ្វីដែរ? (មានសំលេងរំខានពីខាងក្រៅ)

ខ៖ ខ្ញុំមានឈ្មោះនូច ភាព ឈ្មោះ នូច សុភាព!

ក៖ ចាស!

ខ៖ អឹម....

ក៖ ហើយការសំភាសន៍ថ្ងៃនេះធ្វើឡើងនៅថ្ងៃទី១២ ខែ០៧ ឆ្នាំ២០១៨ ហើយអញ្ចឹងអី....ខ្ញុំសុំៗឈ្មោះអ៊ីម្តងទៀត?

ខ៖ ខ្ញុំឈ្មោះ នូច សុភាព!

ក៖ អ៊ីឈ្មោះនិងត្រូវជាមួយនិងអត្តសញ្ញាណប័ណ្ណដែរឬទេ?

ខ៖ ចាស!

ក៖ ចុះអី....ក្រៅពីឈ្មោះមួយនិង តើអ៊ីមានឈ្មោះហៅក្រៅទៀតទេ?

ខ៖ អត់មានឈ្មោះហៅក្រៅទេមានតែឈ្មោះមួយនិងទេ! (មានសំលេងរំខានពីខាងក្រៅ)

ក៖ ចុះអី....ឈ្មោះនិងអ្នកណាជាអ្នកដាក់អោយអ៊ីដែរ?

ខ៖ អី....ឪពុកម្តាយរបស់ខ្ញុំគាត់ជាអ្នកដាក់អោយខ្ញុំ ខ្ញុំអត់ប្តូរទេ កាលនិងឪពុកម្តាយរបស់ខ្ញុំជាអ្នកដាក់ឈ្មោះនិងអោយអញ្ចឹងគឺខ្ញុំអត់ប្តូរទេ ខ្ញុំអត់ប្តូរនាមត្រកូលទេ!

ក៖ អ៊ីមានអត្តសញ្ញាណប័ណ្ណទេ?

ខ៖ ខ្ញុំមាន!

ក៖ អញ្ចឹងខ្ញុំសុំថតបន្តិចមក! (មានសំលេងរំខានពីខាងក្រៅ)

ខ៖ ចាស!

ក៖ ចាស!

គ៖ អានឹងអ៊ីជារបស់ខ្ញុំ!

កៈ និងហើយៗ!

ខៈ ឈ្មោះមួយនិងឪពុកម្ដាយជាអ្នកដាក់អោយអញ្ចឹងមិនមែនយើងចេះតែដាក់ខ្លួនឯងទេ!

កៈ ចាស! អឺ

គៈ អឺថតបញ្ច្រាសនិង!

កៈ ចាស! (ត្រូវហើយ) ហើយអឺ....អឺហើយឈ្មោះអឺអត់មានឈ្មោះហៅក្រៅទេ?

ខៈ អត់ៗមានទាំងអស់អត់មានទេ!

កៈ ចុះអឺ....ឪពុកម្ដាយរបស់អឺមានបានប្រាប់ទេថាឈ្មោះនិងមានអត្ថន័យយ៉ាងមិចទេ?

ខៈ ទេដូចជាគាត់អត់មានប្រាប់អីទេគ្រាន់តែគាត់ដាក់ឈ្មោះនិងអោយយើងតែម្ដង!

កៈ អឹម....

ខៈ យើងក៏អត់ដឹងថាឈ្មោះនិងវាមានអត្ថន័យយ៉ាងមិចយើងទើបតែដឹងដែល
យើងវារៀនអត់បានជិតដល់ អញ្ចឹងយើងអត់ដឹងថាឈ្មោះនិងមានអត្ថន័យយ៉ាងមិចទេ
មិនដឹងថាភាសាអង់គ្លេសនិងគេនិយាយថាមិច
ភាសាខ្មែរនិងមានអត្ថន័យយ៉ាងមិចយើងអត់បានដឹងទេ
យើងដឹងត្រឹមតែថាឈ្មោះនិងឪពុកម្ដាយជាអ្នកដាក់អោយយើងតាំងពីកើតមករហូតមកដល់
សព្វថ្ងៃនិង គឺយើងអត់ប្ដូរឈ្មោះអត់ប្ដូរត្រកូលគឺខ្ញុំប្រើតែឈ្មោះនិងមួយទេ
កាលណាបើយើងប្ដូរឈ្មោះប្ដូរត្រកូលទៅ វាដូចជាថាយើងនិងមើលងាយឪពុកម្ដាយយើងពេក
ឪពុកម្ដាយដែលគាត់ខំដាក់អោយយើងនិងដើម្បីអោយយើងចងចាំឈ្មោះនិង
គឺយើងត្រូវតែយកឈ្មោះនិងមកប្រើ! (មានសំលេងរំខានពីខាងក្រៅ)

គៈ សូម្បីតែក្មួយក៏ហៅអឺដែរ!

កៈ ចុះឪពុកម្ដាយរបស់អឺគាត់មានឈ្មោះអ្វីដែរ?

ខៈ ឪពុកម្ដាយរបស់ខ្ញុំមានឈ្មោះ ម្ដាយខ្ញុំមានឈ្មោះ ភី ង៉ូវ ឪពុកខ្ញុំមានឈ្មោះ នូច ស៊ុន!

កៈ ចុះពួកគាត់មានស្រុកកំណើតនៅឯណាដែរ?

ខ៖ ពួកគាត់មានស្រុកកំណើតនៅខេត្តតាកែវ!

ក៖ ចុះអ៊ីមានស្រុកកំណើតនៅឯណាដែរ?

ខ៖ ខ្ញុំមានស្រុកកំណើតនៅតាកែវដែរ!

ក៖ ចុះអ៊ីរស់នៅភូមិឃុំណាដែរអ៊ី?

ខ៖ ខ្ញុំរស់នៅភូមិឃុំអ៊ី....នៅស្រុកសំរោង ភូមិអ៊ឺ....ស្រុកសំរោងខេត្តតាកែវ នៅភូមិឃុំជំរះពេន!

គ៖ បើៗខ្ញុំវិញនៅបាត់ដំបង!

ក៖ អូ....

ខ៖ នៅឃុំជំរះពេន!

ក៖ ចាស! ចុះសព្វថ្ងៃនេះវិញអ៊ីរស់នៅឯណាដែរ?

ខ៖ ខ្ញុំសព្វថ្ងៃនេះខ្ញុំមកតាមប្តីនិងគាត់ធ្វើសំណង់
និងធ្វើការនៅស្នាក់នៅសំណង់តាមអគារសំណង់ដែលគេធ្វើនិងយើងស្នាក់នៅកន្លែងសំណង់
និងតែម្តង! (មានសំលេងរំខានេពីខាងក្រៅ)

ក៖ អ៊ឹម....ចាស

ខ៖ ចាស!

ក៖ អញ្ចឹងសព្វថ្ងៃអត់មានទីលំនៅពិតប្រាកដទេហ៎?

ខ៖ អត់មានទីលំនៅពិតប្រាកដទេ បើកាលណាប្តីខ្ញុំនៅធ្វើការទៅ
ប្តីធ្វើការនៅកន្លែងណាហើយកន្លែងនិងទៅយើងចូលមកនៅអត់មានទីលំនៅពិតប្រាកដទេ!
(មានសំលេងរំខានពីខាងក្រៅ)

ក៖
អ៊ឹម....ចុះប៉ុន្មានឆ្នាំហើយដែលអ៊ីបានធ្វើការអ៊ឺ....ដូចជាធ្វើជាមួយលោកពូហើយបានស្នាក់នៅទី
នេះ?

ខ៖ អ៊ឺ....បានរយះពេលប្រាំឆ្នាំហើយ!

កៈ ប្រាំឆ្នាំហើយ?

ខៈ ចាស!

កៈ ប្រាំឆ្នាំនិងអ៊ីទៅនៅណា ហើយបានផ្លាស់ទីនំនៅទៅនៅឯណាទីណាដែរអ៊ី?

ខៈ និយាយទៅវា.... បើនិយាយរួមទៅនៅទីក្រុងភ្នំពេញនិងនៅអឺ....ស្ពានជ្រោយចង្វារនិងទៅនៅទឹកខ្មៅ យើយនិងទួលសង្កែ បឹងទំពន់អើយ....នៅណាៗទៀតទេមិនសូវចាំទេ( សើច)!

កៈ មានច្រើនកន្លែងណាស់!

ខៈ មានច្រើនកន្លែងពេកចាំមិនអស់ទេវាមានច្រើនកន្លែងពេក ពីព្រោះចេញពីធ្វើការមួយកន្លែងទៅធ្វើការមួយកន្លែងក្នុងមួយកន្លែងធ្វើសុទ្ធតែពីរបីឆ្នាំ!

កៈ ចាស!

ខៈ ដូចថាវា...ផ្លាសប្តូរទៅទីនេះខ្លះទៅទីនោះខ្លះទៅវាចេះតែភ្លេចអស់អញ្ចឹងទៅណាស់!

កៈ ចាស!

ខៈ យើងភ្លេចខ្លះចាំបានខ្លះមិនចាំបានទាំងអស់ទេ!

កៈ ចាស!

ខៈ
ថាអូ....អូនអើយជីវិតនោះតស៊ូនោះតាំងពីបាតដៃទទេដល់រហូតៗដល់យើងបានប៉ុននេះហ៎មិនទាន់បានធូរធារប៉ុន្មានទេ
យើងនៅលំបាកគ្រាន់តែថាបានត្រឹមមួយកែៗ(បានមួយរស់ៗ)និងហើយវាលំបាកណាស់!

កៈ ចាស! ហើយអ៊ី....លោកពូប្រុសគាត់មានឈ្មោះអ្វីដែរ?

ខៈ អឺ....គាត់មានឈ្មោះ ចឹម ហោង! (មានសំលេងរំខានពីខាងក្រៅ)

កៈ លោកពូគាត់មានស្រុកកំណើតនៅឯណាដែរ?

ខៈ អឺ....គាត់មានស្រុកកំណើតនៅខេត្តព្រៃវែង!

កៈ ចុះអ៊ី មុនដំបូងកាល អ៊ីរៀបការជាមួយគាត់និងនៅក្នុងឆ្នាំណាដែរ?

ខ៖ ខ្ញុំរៀបការនៅឆ្នាំអឺ....ក្នុងឆ្នាំ២០១៥!

ក៖ អ៎....រៀបការទើបតែបានបីឆ្នាំ!

ខ៖ អឺ....មើល....មួយពាន់អឺ....២០១៥ អញ្ចឹងហើយហី!

ក៖ រៀបការតាំងតែពីឆ្នាំ២០១៥ មកដល់ឥឡូវនេះរៀបការបានរយៈពេលបីឆ្នាំហើយ បានបីឆ្នាំហើយពីព្រោះឥឡូវនេះឆ្នាំ២០១៨ បានបីឆ្នាំហើយ (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ បានបួនឆ្នាំហើយ ចាស ខ្ញុំរៀបការក្នុងឆ្នាំ២០១៤!

ក៖ ចាស!

ខ៖ ចូល....បើនិយាយរួមចូលក្នុងខែមួយនិងឆ្នាំ២០១៥ និងអញ្ចឹងហើយ!

ក៖ ចាស!

ខ៖ ចាស!

ក៖ ហើយអឺ....អឺរៀបការមុនដំបូងដោយសារការស្រលាញ់គ្នាក៏ឪពុកម្តាយជាអ្នករៀបចំទុកដាក់អោយ?

ខ៖ អឺ....ពួកខ្ញុំដូចថា....ពួកខ្ញុំរាងចាស់ចិត្តចាស់គំនិត ពីមុននិងខ្ញុំមានគ្រួសារម្តងរួចមកហើយប៉ុន្តែខ្ញុំបែកបាក់គ្នា!

ក៖ ចាស!

ខ៖ ដល់ពេលបានគាត់មកនិងគាត់គឺជាគ្រួសារក្រោយទេ!

ក៖ អឹម....

ខ៖ ដល់ពេលអញ្ចឹងទៅពួកខ្ញុំឃើញគ្នាទៅអើ....ដូចថាចាស់ៗហើយយើងចេះតែយល់ចិត្តគ្នាទៅរួចក៏ការទៅ កាន់ដៃគ្នាទៅ! (មានសំលេងរំខានពីខាងក្រៅ)

ក៖ ចាស! ចុះអឺ....ប្តីរបស់អឺក្រោយនិងគាត់ធ្លាប់មានប្រពន្ធមុនដែរឬទេ?

ខ៖ គាត់ធ្លាប់មានប្រពន្ធមុនដែរ ប៉ុន្តែប្រពន្ធមុនរបស់គាត់បានស្លាប់ហើយ!

កៈ ចុះគាត់មានកូនដែរឬទេ?

ខៈ ប្ដីរបស់ខ្ញុំគាត់មានកូនប្រាំនាក់!

កៈ អូ....គាត់មានកូនច្រើន!

ខៈ ចាស!

កៈ (សើច)

ខៈ នៅក្នុងបន្ទុកហើយនិងមានកូនប្អូនទៅប្រាំនាក់ទៀតសព្វថ្ងៃនិង!

កៈ លោកពូគាត់មានអាយុប៉ុន្មានហើយ?

ខៈ គាត់មានអាយុ៥៦ឆ្នាំហើយ!

កៈ អ៊ី....ហើយចុះអ៊ីវិញមានអាយុប៉ុន្មានហើយ?

ខៈ ខ្ញុំមានអាយុ៤៦,៤៦ អីអស់និង! (មានសំលេងរំខានពីខាងក្រៅ)

កៈ ចាស! ចុះកូនរបស់អ៊ី អឺ....កូនរបស់អ៊ីមុនហាសមានដែរឬទេ?

ខៈ ខ្ញុំអត់មានកូនទេ!

កៈ ចុះប្ដីអ៊ីមុនគាត់មានឈ្មោះអ្វីដែរ?

ខៈ អ៊ឹម....ដូចជារាងភ្លេចហើយអូនតាំងពីកៅជាងឯណោះនិង (ឆ្នាំ១៩៩០ជាង)!

កៈ ចាស!

ខៈ
ដូចជាអត់បានចាំទេដឹងត្រឹមតែថាគាត់ឈ្មោះអឺ....សម្បិត្តប៉ុន្តែខ្ញុំភ្លេចឈ្មោះត្រកូលរបស់គាត់បាត់ទៅហើយ!

កៈ ចាស! តើប្ដីមុនរបស់អ៊ីនិង អ៊ីបានស្រលាញ់គ្នាដែរឬទេ?

ខៈ អត់បានស្រលាញ់ទេគឺឪពុកម្ដាយជាអ្នករៀបចំទុកដាក់អោយ!

កៈ ចាស! ចុះប្ដីរបស់អ៊ីគាត់ស្លាប់ដោយសារអ្វីដែរ?

ខ៖ ប្ដីខ្ញុំគាត់អត់បានស្លាប់ទេគាត់និងខ្ញុំបានលែងគ្នា!

ក៖ ចាស! អញ្ចឹងទេហ៎!

ខ៖ ចាស!
បើយើងជាធម្មតាទេប្រសិនបើយើងមិនអាចរស់នៅជាមួយគ្នាបានយើងមានតែចែកផ្លូវគ្នាទៅ!
(មានសំលេងរំខានពីខាងក្រៅ)

ក៖ ចាស!

ខ៖ ចាស!

ក៖ អោយខ្ញុំសុំទោសអ៊ីផង ពេលដែលបានលឺអញ្ចឹងនិងណាស់
ជាធម្មតាទេប្រសិនបើក្នុងគ្រួសារទៅអញ្ចឹងហើយអ្នកណាមិនចង់បានអញ្ចឹងដែរ!

ខ៖ ចាស! ចាស!

ក៖ ចាស! តែអ៊ីកាលនិងអ៊ីអត់មានកូនទេណ៎!

ខ៖ ខ្ញុំគ្មានកូនទេ!

ក៖ ចុះរៀបការប្ដីក្រោយអ៊ីមានកូនដែរឬទេ?

ខ៖ អឺ....អត់ដែរ!

ក៖ ចាស!

ខ៖ ចាស! (មានសំលេងរំខានពីខាងក្រៅ)

ក៖ អញ្ចឹងកូនអឺ....កូនរបស់លោកពូដែលត្រូវជាស្វាមីរបស់អ៊ីគាត់មានកូនទាំងប្រាំនាក់
ចុះកូនប្រាំនាក់និងគាត់មានឈ្មោះអ្វីខ្លះដែរទៅ?

ខ៖ អឺ....ពួកគាត់មានឈ្មោះ ហោង វាស្នា ហោង ប៉ុណ្ណា ហោង ស្រីនាង ហោង ស្រី...អ៊ឹម.... ហោង
ឈុនី អឺ....និង ហោង រ៉ាវី និង ហោង រ៉ាវុធ!

ក៖ ចាស!

ខ៖ ចាស!

កៈ ចុះពួកគាត់ទាំងអស់គ្នាគាត់និងបានធ្វើការអស់ហើយឫនៅ?

ខៈ គាត់បានធ្វើការ បានខ្លះហើយ!

កៈ ចាស!

ខៈ ចាស!

កៈ ពួកគាត់មានមុខរបរធ្វើអ្វីខ្លះទៅ?

ខៈ គាត់ធ្វើការសំណង់ សុទ្ធតែនាក់សំណង់!

កៈ អញ្ចឹងគាត់ជួយធ្វើការងារឪពុកហើយ (សើច)!

ខៈ ចាស! អត់មានទេវាជួយគ្រួសារវាទៅ!

កៈ គាត់មានកូនស្រីប៉ុន្មាននាក់ប្រុសប៉ុន្មាននាក់ដែរ?

ខៈ គាត់មានកូនស្រីតែមួយទេតែកូនប្រុសមានបួននាក់ប្តីខ្ញុំនិង!

កៈ កូនស្រីគាត់ធ្វើការងារសំណង់ដែរ?

ខៈ ចាស! និងហើយធ្វើសំណង់!

កៈ (សើច) ចុះអ៊ីអឺ....បងប្អូនអ៊ីវិញ?

ខៈ អឺ....បងប្អូនរបស់ខ្ញុំមានតែបួននាក់ទេ!

កៈ ស្រីប៉ុន្មាននាក់ហើយប្រុសប៉ុន្មាននាក់?

ខៈ បងប្អូនរបស់ខ្ញុំមានស្រីបីនាក់ហើយប្រុសម្នាក់!

កៈ អូ....គាត់មានឈ្មោះអ្វីដែរអ៊ី?

ខៈ ឈ្មោះខ្ញុំនិងឈ្មោះ នួច សុភាព អាប្រុសនិងឈ្មោះ នួច វ៉ាន់ឌឿន ហើយម្នាក់ទៀតឈ្មោះ នួច សាមុត ហើយនិង នួច ភ័ណ្ឌា!

កៈ អំ....ចាស ចុះអ៊ីកូនបងគេហ៎?

ខៈ ចាស! ខ្ញុំកូនបងគេ! (មានសំលេងរំខានពីខាងក្រៅ)

ក៖ អឺ....ពួកគាត់ទាំងអស់គ្នារៀបការអស់ហើយនិងមានក្រុមគ្រួសារអស់ហើយ!

ខ៖
រៀបការអស់ហើយមានគ្រួសារអស់ហើយតែគ្រាន់តែថានៅជាប់មានបន្ទុកជាមួយគ្នាទាំងអស់និងណាស់!

ក៖ ចាស!

ខ៖ ចាស!

ក៖ ចុះសព្វថ្ងៃអ៊ីមានសមាជិកនៅជាមួយគ្នាមានប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំសព្វថ្ងៃខ្ញុំនៅខាងប្ដីខ្ញុំ!

ក៖ អ៊ី....ដូចជានៅជាមួយជុំគ្នាទាំងអស់!

ខ៖ ខាងម្ដាយរបស់ខ្ញុំនិងហ៎ខាងខ្ញុំ!

ក៖ នៅទាំអស់គ្នានិងតែម្ដង!

ខ៖ ទាំងអស់ខ្ញុំនៅតែពីរបីនាក់ប្អូនទេ ហើយនិងម្ដាយហើយប្ងូនាក់ទាំងប្ដីវា!

ក៖ អ៊ឹម....ម្ដាយរបស់អ៊ីនៅជាមួយដែរហ៎?

ខ៖ ម្ដាយរបស់ខ្ញុំនៅជាមួយដែរ!

ក៖ ម្ដាយរបស់អ៊ីគាត់មានអាយុប៉ុន្មានហើយ?

ខ៖ ម្ដាយរបស់ខ្ញុំគាត់មានអាយុអឺ....ហុកសិបពីរឆ្នាំ (៦២ឆ្នាំ) គាត់អាយុ៦២ឆ្នាំហើយ!

ក៖ ចាស!

ខ៖ ចាស! (មានសំលេងរំខានពីខាងក្រៅ)

ក៖
អឺ....អញ្ចឹងគេអោយនៅលក្ខណៈអញ្ចឹងគេអត់អឺ....ថ្លៃទឹកភ្លើងអញ្ចឹងគេអោយយើងចេញទេ?

ខ៖ អត់ទេគាត់នៅអឺ....គេអត់អោយយើងចេញទេគេជាអ្នកចេញទាំងអស់និង!

កៈ អំ....

ខៈ ចាស! អញ្ចឹងហើយ!

កៈ ហើយអ៊ី....អ៊ីសព្វថ្ងៃបានប្រាក់ចំណូលអី....អីនិងលោកពូជាអ្នកអោយ!(មានសំលេងរំខានពីខាងក្រៅ)

ខៈ ចាស! អញ្ចឹងគាត់ជាអ្នកចេញអោយប៉ុន្តែគាត់មិនចេញអោយច្រើនទេចេញត្រឹមបួនប្រាំម៉ឺនអីនិង!

កៈ (សើច) ចុះអ៊ី....អ៊ីអាចរកប្រាក់ចំណូលបានដោយខ្លួនឯងបានដែរទេ?

ខៈ ខ្ញុំរកអត់បានផង!

កៈ អញ្ចឹង....

ខៈ ចាស! បើយើងនៅមើលចៅអោយកូនអញ្ចឹងយើងអត់មានបានធ្វើអីទេគ្មានប្រាក់ចំណូលមានតែប្តីទេរកបាន!

គៈ លោកយាយ....

កៈ ចាស! អ៊ីមុននិងរៀបការអ៊ីមានមុខរបរអី ហើយមានធ្វើការអីទេ?

ខៈ ខ្ញុំ....មុននិងខ្ញុំការខ្ញុំនៅធ្វើការអោយគេនិង! (មានសំលេងរំខានពីខាងក្រៅ)

កៈ អ៊ីធ្វើការខាងអីគេដែរ?

ខៈ ធ្វើនៅក្នុង...ខាងគុយទាវ ហាងគុយទាវ!

កៈ អញ្ចឹងអ៊ីចេះធ្វើគុយទាវហើយ!

ខៈ ចាស! អឹម....

កៈ ធ្វើគុយទាវបើគុយទាវស្រុះគុយទាវ....?

ខៈ ស្រុះគុយទាវលក់អីនិងលក់តាមហាង!

កៈ ចាស! ហើយការងារនិងមានតែមួយនិងទេណោះអ៊ីណោះ?

ខៈ ចាស! ចាស! មានតែមួយនិង!

កៈ ចុះកាលអ៊ីរៀន អ៊ីរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខៈ កាលនិងខ្ញុំរៀនបានត្រឹមថ្នាក់ទីពីរទេអូនអើយ ហើយឈប់រហូតរៀនគ្មានចេះអីទេ!

កៈ មិចបានអ៊ីរៀនបានត្រឹមតែថ្នាក់ទីពីរអញ្ចឹង? (មានសំលេងរំខានពីខាងក្រៅ)

ខៈ ចុះបើ ដូចខ្ញុំនិយាយអញ្ចឹងយើងជួបការលំបាក ខ្ញុំក្នុងឆាកជីវិតដែរយើងខំតស៊ូទៅ
អញ្ចឹងយើងមិនអាចរៀនបន្តទៀតបាន
មើលទៅឪពុកម្តាយយើងគាត់ក៏លំបាកហើយប្អូនវានៅតូចៗនិង ដល់អញ្ចឹងយើង
យើងនៅតស៊ូរកស៊ីចិញ្ចឹមប្អូនទៅ! (មានសំលេងរំខានពីខខាងក្រៅ)

កៈ ហើយកាលនិងអ៊ីរៀនបានត្រឹមថ្នាក់ទីពីរមានចេះសរសេរចេះអានដែរឬទេ?

ខៈ កាលនិងអត់ចេះទេបើអានចេះបើសរសេរវិញទេ!

កៈ ភាសាអីអស់និងអ៊ីមានបានរៀនដែឬទេ?

ខៈ អត់ទាំងអស់រៀនតែភាសាខ្មែរនិង!

កៈ ចេះតែភាសាខ្មែរ?

ខៈ ភាសាខ្មែរនិងរៀនមិនចេះផង!

កៈ អ៊ីចេះតែភាសាខ្មែរនិងមួយ?

ខៈ ចាស!

កៈ ចុះអ៊ីមានបងប្អូននៅក្រៅប្រទេសទេ?

ខៈ ខ្ញុំអត់មានបងប្អូននៅក្រៅប្រទេសទេ ខ្ញុំមានតែបងប្អូនបួននាក់និងតែម្តង!

កៈ អ៎....ការជំនាន់ប៉ុលពតគេបានជំលៀសអ៊ីទៅខាងណាដែរ?

ខៈ ខ្ញុំអត់បានទាន់ផង!

កៈ អឹម....កាលនិងនៅតូចពេក!

ខៈ ចាស! កាលនិងយើងនៅតូចអញ្ចឹងអត់បានដឹង ចាស
យើងអត់ដឹងដល់ពេលសួររឿងនិងយើងអត់ដឹង និយាយរួមអត់ដឹងតែម្ដង!

កៈ អត់មានការចងចាំនិងរឿងនិង!

ខៈ អត់បានដឹង!

កៈ គ្រាន់តែដឹងថាកាលពីតូចនិងតែចាំអត់បាន!

ខៈ ចាស! យើងអត់បានដឹងតាំងពីតូចមកគ្រាន់តែដឹងថាស្រុកយើងគេស្រួលបួលតែម្ដង!

កៈ អឹម....

ខៈ យើងអត់ដឹងថាពីជំនាន់នោះយ៉ាងមិចៗទេអត់ដឹង!

កៈ ចុះជំនាន់កាលសម័យអ៊ីវិញអ៊ីអ៊ី....កាលនៅពីក្មេងៗនិងចូលចិត្តលេងល្បែងលេងអីទេ?

ខៈ អត់ទេ គឺ....ចូលចិត្តស្ងាត់ស្ងៀមអត់ចូរចិត្តនិយាយស្ដីអត់ចូរចិត្តនិយាយច្រើន!

កៈ ចាស!

ខៈ ខ្ញុំចូរចិត្តតែរកលុយធ្វើការងារ!

គៈ ចូរចិត្តរៀន!

កៈ ចូរចិត្តរៀន (សើច) ហើយអឺ....ទាក់ទងជាមួយបទចំរៀងអីអ៊ីចូរចិត្តឫអត់?

ខៈ អត់ចូរចិត្តទេ!

កៈ អូ....ចាស!

ខៈ ចាស! អត់ដែរច្រៀងអត់ដែរអីទេ! (មានសំលេងរំខានពីខាងក្រៅ)

កៈ ចុះកាលពីតូចអ៊ីធ្លាប់មានក្ដីស្រមៃចង់ធ្វើការងារអ្វីទេ

ខៈ
អេ....ក្ដីស្រមៃរបស់ខ្ញុំពេលធំឡើងអឺ....អញ្ចឹងទៅខ្ញុំចង់រកមុខរបរអ្វីមួយដើម្បីចិញ្ចឹងជីវិតយើង!

ក៖ ចាស! ចុះឥឡូវនិងអ៊ីមានគំរោងចង់ធ្វើអ្វីដែរ?

ខ៖ ខ្ញុំដូចជាគ្មានគំរោងចង់ធ្វើអ្វីផង
ពីព្រោះយើងអត់មានលទ្ធភាពដល់អញ្ចឹងយើងអត់មានគំរោងអីផង!

ក៖ អ៊ីនៅក្នុងជីវិតរបស់អ៊ីនៅក្នុងជីវិតរបស់អ៊ី
អ៊ីធ្លាប់ជួបការលំបាកអ្វីខ្លះដែលធ្វើអោយអ៊ីចាំមកដល់ឥឡូវអត់ភ្លេចសោះឡើយ?

ខ៖ ចាស! មិនដែរបំភ្លេចទេគឺដោយសារយើងជួបការលំបាកជីវភាពរបស់យើងក្រ
យើងមានគេតិះដៀលយើងធ្វើអោយយើងមានការចងចាំនៅក្នុងជីវិត ចាស
ដូចថាយើងពេលយើងមេម៉ាយអត់មានគ្រួសារអញ្ចឹងទៅ
ដូចថាឪពុករបស់យើងស្លាប់ម្ដាយយើងដូចថាគាត់ហូបស្រាហូបអីនិងអញ្ចឹងអីទៅបងប្អូនគេ
ចេះតែមើលងាយទៅណាស់ អញ្ចឹងយើងចងចាំទៅយើងចាំគ្មានថ្ងៃភ្លេចទេអូន
អញ្ចឹងយើងលំបាកទំរាំតែបានដល់សព្វថ្ងៃនិង ចាស មានតែប៉ុណ្ណឹង!
(មានសំលេងរំខានពីខាងក្រៅ)

ក៖
ចុះចំពោះបទពិសោធន៍ល្អៗនៅក្នុងជីវិតដែលធ្វើអោយអ៊ីសប្បាយចិត្តរឿងដែលធ្វើអោយអ៊ីនឹក
ឃើញហើយសប្បាយចិត្ត តើមានដែរឬទេអ៊ី?

ខ៖ រឿងដែលល្អៗធ្វើអោយខ្ញុំសប្បាយចិត្តមានតែឃើញម្ដាយរបស់យើងគាត់មានសុខភាពល្អ
ខ្ញុំចង់អោយគាត់រស់នៅបានយូរ
និយាយទៅយើងចង់អោយគាត់សប្បាយចិត្តយើងក៏សប្បាយចិត្តតាមគាត់និងទៅ!
(មានសំលេងរំខានពីខាងក្រៅ)

ក៖ អូ....ចាស ល្អមែនទែនដែលគាត់រស់នៅមានជីវិតហើយសប្បាយចិត្ត!

ខ៖ ចាស!

ក៖
អ៊ីធ្លាប់ឆ្លងកាត់មកយ៉ាងច្រើនរាប់មិនអស់ទេប៉ុន្តែអ៊ីអាចចែកចាយដើម្បីអោយកូនចៅជំនាន់

ក្រោយដើម្បីអោយពួកគេបានដឹងអំពីជីវិតរបស់អ៊ី តើអ៊ីបានធ្លាប់ឆ្លងកាត់ជីវិតអីគេខ្លះ ហើយមានការតស៊ូអីគេខ្លះនៅក្នុងជីវិត និងការតាំងចិត្តព្យាយាមយ៉ាងណាដែរពីមុនមក?

ខ៖ ចាស! ខិតខំតស៊ូព្យាយាម ហើយខ្ញុំចង់អោយចៅៗ បងប្អូន
ក្មួយៗជំនាន់ក្រោយអោយខំប្រឹងរៀនអោយបានចេះដឹង
រៀនទៅកុំអោយល្ងង់ដូចយើងតាំងពីជំនាន់មុនដើម្បីវាចេះតស៊ូ
និងអោយវាដឹងទៅថាការលំបានវាវេទនាណាស់អូនអើយ យើងតស៊ូទំរាំបានប៉ុននេះ
អញ្ចឹងសូមផ្តាំទៅក្មេងៗជំនាន់ក្រោយនេះ
ដើម្បីអីសម័យនេះហើយគឺជាសម័យដែលជឿនលឿនណាស់អោយវាខំប្រឹងរៀនទៅ
ដើម្បីយកចំណេះវិជ្ជារកស៊ីចិញ្ចឹងជីវិតកុំអោយវាលំបាកទៅដល់ថ្ងៃមុខទៀតខ្ញុំមានតែប៉ុណ្ណឹង!
(មានសំលេងរំខានពីខាងក្រៅ)

កៈ ចុះអ៊ីមានការលំបាកអីគេខ្លះទៅ?

ខ៖ អឺម....ការលំបាករបស់ខ្ញុំនិងមានច្រើនណាស់អូនកាលណា
ជាធម្មតាយើងនៅស្រុកស្រែនឹកឃើញគ្រប់សព្វ
ជូនកាលឆ្នាំងនៅផ្ទះយើងទៅអង្ករនៅផ្ទះគេទៅណាអូនពេលដែលយើងឡើងមកផ្ទះអញ្ចឹង
ហើយអត់អង្ករនិងអញ្ចឹងយើងមានតែកណ្តៀតកញ្ជើទៅរកអង្ករផ្ទះគេជូនកាលគេឆ្លើយថាគេអ
ត់មានអញ្ចឹងទៅ យើងក៏មិនដឹងថាយើងទៅរកអីមានតែយើងមានប៉ុន្មានយើងហូបប៉ុណ្ណឹងទៅ
វាលំបាកណាស់កាលលំបាកវាមិនមានអត់ មានការលំបាកច្រើន!

កៈ ចាស!

ខ៖ ខិតខំតស៊ូទំរាំតែបានមកប៉ុណ្ណោះវាឆ្អែតអស់ហើយឆាកជីវិតនោះ!

កៈ អញ្ចឹងអ៊ី....កាលសម័យនិងអ៊ីមានធ្វើស្រែធ្វើចំការដែរហាំ?

ខ៖ ចាស....?

កៈ ថាកាលសម័យមុនអ៊ីមានធ្វើស្រែធ្វើចំការដែលហាំ?

ខ៖ ធ្វើៗស្រែដល់សព្វថ្ងៃនិងប៉ុន្តែមកដល់តឡូវក៏នៅតែធ្វើដែរ
កាលណាប្រសិនបើយើងអត់ធ្វើយើងអត់មានអីហូប!

កៈ អ៊ីធ្វើស្រែប្រាំងឬស្រែវស្សា? (មានសំលេងរំខានពីខាងក្រៅ)

ខៈ ស្រែអ៊ី....ធ្វើស្រែខែវស្សា
ធ្វើតែស្រែវស្សានិងអត់មានធ្វើស្រែប្រាំងពីព្រោះអ៊ីធ្វើបានតែមួយប្រាំងទេក្នុង
មួយឆ្នាំធ្វើបានតែម្តងទេ ស្រុកតាកែវនិងហ៎!

កៈ ចាស!

ខៈ ចាស!

កៈ ចុះអ៊ីធ្វើស្រែនិងដីខ្លួនទេហ៎?

ខៈ ចាស! ធ្វើស្រែដីខ្លួនឯង!

កៈ អ៊ីធ្វើស្រែម្តងៗប៉ុន្មានដែរ? (មានសំលេងរំខានពីខាងក្រៅ)

ខៈ ធ្វើម្តងៗបើនិយាយរួមទៅប្អូនខ្ញុំគេជាអ្នកធ្វើគេមានអ្នកធ្វើ
ធ្វើបានម្តងៗវាបានសាមសែសិបថាំងអញ្ចឹងទៅ!

កៈ ហូបគ្រាន់ដែរឬទេអ៊ី?

ខៈ ហូបមួយឆ្នាំល្មមម៉ាហូបមួយគ្រប់ៗជូនកាលគ្រប់ជូនកាលអត់គ្រប់អញ្ចឹងទៅ ថ្ងៃ ខែ
ឆ្នាំណាយើងធ្វើបានល្អទៅយើងបានល្អទៅវាបានឡើងទៅណាស់
ឆ្នាំណាដូចថាវាទឹកភ្លៀងមិនសូវអំណោយផលទៅយើងក៏មិនសូវបានផលទៅអញ្ចឹងដែរ
វាមិនមែនអង្គុយតែបានរហូតអញ្ចឹងទេ!

កៈ ចុះខែដែលទទួលបានផលច្រើនជាងគេបានប៉ុន្មានដែរអ៊ីបើសរុបទាំងអស់?

ខៈ
វា....ក្នុងឆ្នាំដែលទទួលបានផលជាងគេនិងវាមិនដឹងឆ្នាំណាទៀតនិងពីព្រោះអ៊ីមិនមែនជាអ្នក
ធ្វើផងប្អូនគេជាអ្នកធ្វើ
យើងគ្រាន់តែថាយើងអោយលុយវាបន្តិចបន្តួចដើម្បីអោយជួលគេឯងជួលគេអោយស្ទូងអោយ
អីទៅអញ្ចឹងណាស់!

កៈ ដល់ពេលបានផលមកយកមកចែកគ្នាអញ្ចឹងទៅ?

ខ៖ និងហើយ អត់មានចែកទេទុកអោយម្ដាយរបស់ខ្ញុំអីនិងទៅទុកអោយគាត់ហូប ពេលដែលគាត់ហូបហើយគាត់ឈឺអីនិងទៅយើងលក់មើលគាយ់អីខ្លះទៅអញ្ចឹងណាស់!

ក៖ អូ....

ខ៖ ពីព្រោះយើងវាអត់អញ្ចឹងតតែយើងចេះរំលែកអញ្ចឹង!

ក៖ អញ្ចឹងការចំណាយរបស់អ៊ីចំណាយទៅលើគាត់ក្នុងការដាំស្រូវនិង តើអ៊ីចំណាយអស់ប៉ុន្មានដែរ?

ខ៖ ក្នុងមួយអឺ....ឆ្នាំបើនិយាយទៅយើងចំណាយទៅអស់មួយរយដុល្លា!

ក៖អញ្ចឹងអ៊ីចំណាយទៅអស់ទេមួយរយដុល្លាទេ?

ខ៖ ចាស! ហើយឆ្នាំណាជូនកាលយើងអត់រកបានអីអញ្ចឹងទៅ អត់ដែរទៅមិនមែនយើងអង្គុយតែមានរហូតឯណា ជូនកាលយើងអត់មែនទែនយើងអត់បានអោយទេ ប៉ុន្តែយើងផ្ដល់ជាខែអោយគាត់ដូចថាប្ដីអ៊ីបើកលុយមកអញ្ចឹងទៅយើងផ្ដល់អោយគាត់បូនដប់ម៉ឺនរៀលអញ្ចឹងទៅវាអញញ្ចឹងវិញ អ៊ឹម....( មានសំលេងរំខានពីខាងក្រៅ)!

ក៖ អញ្ចឹងក្នុងការរកស៊ីមួយនិងបានសល់អីគេដែលអ៊ីឬទុកតែចែកបងប្អូន?

ខ៖ ទេវានមិនបានច្រើនទេទុកតែចែកអោយបងប្អូនទៅណាស់ពេលណាបងប្អូនអត់ស្រូវអញ្ចឹងទៅ ហើយយើងអត់នេះដែរទៅត្រូវការចាក់ថ្នាំចាក់អីអោយម្ដាយអញ្ចឹងទៅយើងបណ្ដោះមួយកញ្ចើរពីរកញ្ចើរអីនិងទៅហើយយកលុយនិងមកចាក់ថ្នាំអោយម្ដាយនិងវាអញ្ចឹង ប៉ុន្តែប់មានលុយជាធំដំវាអត់មានទេ!

ក៖ អ៎....

ខ៖ ចាស! យើងអត់មានទេលក់ធំដំហ៎!

ក៖ ថាបើអ៊ីមានរកទៅទិញពីព្រោះអីនៅខេត្តតាកែវខាងអីនិងគាត់ធ្វើស្រែអត់សូវប្រើជីទេ?

ខ៖ និងហើយអត់ទេអត់មានទេ
ហើយអត់ប្រើជីទេពីព្រោះអីយើងថាអឺ....យើងអត់អញ្ចឹងប្អូនៗអីនិងវាអត់អើលក់អោយខ្ញុំមកយកលុយចាក់ថ្នាំពេទ្យអោយម្តាយអីនិងទៅទិញនិងលក់ទៅអញ្ចឹងទៅដល់ពេលបើអោយលក់ជាអាជីពគឺអត់មានទេអូនអត់មានទេនិងហើយបើយើងអត់មានធ្វើស្រូវលក់យើងធ្វើត្រឹមតែមួយហូបៗពីព្រោះស្រែរបស់យើងវារាងតិចដែរ!

ក៖ ចាស!

ខ៖
កាលនិងយើងធ្វើត្រឹមតែមួយហូបៗទេគ្រាន់ថាអើយើងដោះទាល់ពេលដែលឪពុកម្តាយគាត់អត់ស្រួលអញ្ចឹងណាស់ពេលដែលយើងអត់លុយយើងអាចដោះទាល់បានបន្តិចៗអញ្ចឹងទៅមើលគាត់ទៅមានតែប៉ុណ្ណឹងទេ! (មានសំលេងរំខានពីខាងក្រៅ)

ក៖ ចាស! អ៊ីធ្វើស្រូវប្រភេទអ្វីដែរ?

ខ៖ ចាស....?

ក៖ អ៊ីដាំស្រូវប្រភេទអ្វីដរ?

ខ៖ អឺ....ភាគច្រើនខ្ញុំធ្វើស្រូវផ្កាខ្ញី ផ្ការំដួល នាងនួនអីនិងមានតែប៉ុន្មានពូជនិង (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ជាពូជស្រូវដែរឆ្ងាញ់ជាងគេ (សើច)!

ខ៖ ចាស!

ក៖ អ៊ីបានធ្វើស្រូវពីរនិងជារៀងរាល់ឆ្នាំទៅ?

ខ៖
វា....ឆ្នាំណាយើងធ្វើៗទៅឆ្នាំណាដូចថាហូបមិនសូវគ្រប់និងយើងអត់ធ្វើទៅវាអញ្ចឹងណាស់!

ក៖ ចាស!

ខ៖ តែបើស្រូវនិងធ្វើទៅបាយឆ្ងាញ់អញ្ចឹងយើងហូបអត់គ្រប់ទេដាំបាយទៅអត់សូវឡើងនិយាយទៅបើថ្ងៃណាឆ្នាំណាយើងចង់ធ្វើស្រូវនិងទៅយើងត្រូវទៅធ្វើស្រូវនេះផ្សេងទៅដើម្បីយើងយកផលវាតែប៉ុណ្ណឹងទេអូនអស់ហើយ!

កៈ ចាស!
អ៊ីអញ្ចឹងជាចុងក្រោយអ៊ីមានពាក្យពេចន៍អ្វីដើម្បីផ្ដែផ្ដាំទៅអ្នកដែលគេបានស្ដាប់សំលេងអ៊ីនៅក្នុងថ្ងៃនេះអញ្ចឹងទៅណាស់
ដូចជាអឺ....ដូចជាកូនចៅដូចជាអ្នកដែលគេបានចូរទៅស្ដាប់សំលេងរបស់អ៊ីជាពិសេសអឺ....ដូចជាអឺ....អ្នកជិតខាងសាច់ញាតិអ៊ីនិងទៅគេបានស្ដាប់សំលេងអ៊ីអឺ....ថាអ៊ីធ្លាប់មានបទពិសោធន៍ជីវិតអឺ....អ៊ីធ្លាប់ឆ្លងកាត់ហើយគាត់អឺ....ចង់អោយកូនចៅជំនាន់ក្រោយទៀតយ៉ាងណាដែរតាមរយៈសំលេងមួយនេះរបស់អ៊ីដើម្បីនិយាយជាចុងក្រោយ!

ខៈ
ខ្ញុំសុំផ្ដាំទៅបងប្អូនញាតិជិតខាងអ៊ីនិងកូនចៅអ៊ីកូនក្មួយអ៊ីនិងអោយថាអោយខិតខំប្រឹងប្រែងរកនិយាយទៅកុំអោយគេមើលងាយពេលយើងអត់វាលំបាកណាស់ជីវិតតស៊ូតាំងពីដើមតាំងពីក្មេងរហូតមកដល់ចំណាស់នេះហើយមិនទាន់មានសេចក្ដីសុខមិនទាន់មានអ្វីក្នុងខ្លួនទៀតកុំអោយលំបាកទៅថ្ងៃមុខទៀត
អញ្ចឹងខ្ញុំសុំផ្ដាំទៅក្មេងៗជុះនាន់ក្រោយអោយខិតខំរៀនសូត្រយកចំណេះវិជ្ជាដើម្បីចិញ្ចឹមខ្លួនយើង មិនចេះនិយាយទេអូនចេះតែប៉ុណ្ណឹង(សើច)!

កៈ (សើច) ចាស អ៊ី!

ខៈ ចាស!

ខៈ ចាស! អ៊ីនិយាយតែប៉ុណ្ណឹងបានហើយពីព្រោះអីអឺ....នេះជាអ្វីដែលអ៊ីចង់បាន!

ខៈ ចាស!

កៈ ដើម្បីអោយកូនចៅជំនាន់ក្រោយបានស្ដាប់!

ខៈ ចាស!

កៈ ពីព្រោះនេះគឺជាទឹកចិត្តរបស់អ៊ី ជាអ្វីនៅក្នុងចិត្តដែលអ៊ីចង់ប្រាប់គេ!

ខៈ ចាស! (មានសំលេងរំខានពីខាងក្រៅ)

កៈ
អញ្ចឹងវាមិនមែនជាការដែលថាអឺ....យើងចេះតែនិយាយអោយរួចតែយើងនិយាយដោយចេញពីចិត្តមក!

ខៈ ចាស! នេះជាការនិយាយពាក្យពិត និយាយចេញពីចិត្តមកនិយាយពី
ចេញពីចិត្តរបស់ខ្ញុំតែម្ដង

ខ្ញុំអត់នេះទេអត់កុហក់ទេពីព្រោះអីខ្ញុំបានមកប៉ុននេះក៏វាបានលំបាកណាស់មកហើយដែលហាត់នឿយក្នុងឆាកជីវិត
ជូនកាលខ្ញុំនិងទៅដល់ពេលដែលម្ដាយរបស់ខ្ញុំឈឺអញ្ចឹងទៅខ្ញុំអត់លុយជូនកាលខ្ញុំក៏តូចចិត្តខ្លួនឯងមែន ខ្ញុំតូចចិត្តណាស់ណាខ្ញុំរត់ទៅរកលុយគេណាមួយម្ដាយឈឺ
អូយតូចចិត្តណាស់រាល់ថ្ងៃនេះក៏មិនទាន់ថាយើងស្រឡះដែលគ្រាន់តែថាយើងគិតអោយវាវែងឆ្ងាយទៅកុំតូចចិត្តនិងវាសនាអី
និងហើយកុំតូចចិត្តនិងវាសនាអញ្ចឹងយើងតស៊ូទៅមុខទៀតចាំយើងអស់ជីវិតត្រឹមណាយើងគិតត្រឹមនឹងទៅលទ្ធភាពយើងកបានប៉ុណ្ណាយើងយកប៉ុណ្ណឹង
ពេលណាយើងគិតថាយើងចង់អោយមានបនដូចគេវាមិនមានទេមានតែប៉ុណ្ណឹងទេអូន
ក៏មានតែប៉ុណ្ណឹង! (មានសំលេងរំខានពីខាងក្រៅ)

កៈ ចាស! អរគុណច្រើនអ៊ីសំរាប់ការសំភាសន៍ថ្ងៃនិង
ហើយអ៊ី....ខ្ញុំសង្ឃឹមថាថ្ងៃណាមួយក្ដីស្រមៃនិងគោលបំណងនិងគំរោងក្នុងថ្ងៃអនាគត់របស់អ៊ីនិងក្លាយទៅជាការពិត
ហើយសុំអោយកូនចៅជំនាន់ក្រោយដូចជាត្រូវជាកូនរបស់អ៊ីឫក៏មានដូចជាកូនចៅបងប្អូនរបស់អ៊ីដែលគេបានស្ដាប់និងទៅធ្វើអោយគេបានដឹងអំពីប្រវត្តិរបស់អ៊ី
អញ្ចឹងអ៊ីគេអាចនិងជួយដូចជាលើកទឹកចិត្តនិងផ្ដល់កំលាំងចិត្តឫក៏អាចចងក្រងជាឯកសាររបស់កូនចៅជំនាម់ករោយទៀតជាកេរតិ៍កុំអោយបាត់បង់ទៀត!

ខៈ ចាស!

កៈ អញ្ចឹង តើអ៊ីអាចអនុញ្ញាតអោយខ្ញុំយកសំលេងរបស់អ៊ីដាក់បានទេ?
(មានសំលេងរំខានពីខាងក្រៅ)

ខៈ ចាស! យកទៅចុះ!

កៈ ចាស! អរគុណអ៊ី!

ខៈ ខ្ញុំអត់ឃាត់ទេពីព្រោះយើងគ្មានទៅធ្វើអីខុស!

កៈ ចាស! អរគុណច្រើនអ៊ី!

ខៈ ចាស! (មានសំលេងរំខានពីខាងក្រៅ)

កៈ អញ្ចឹងខ្ញុំសូមជូនពរអោយអ៊ីនិងក្រុមគ្រួសាររបស់អ៊ីមានតែសុភមង្គល់!

ខៈ ចាស! ចាស! សាធុៗ (មានសំលេងរំខានពីខាងក្រៅ)